ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក.ស.ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆ្នាំ២០១៩នេះ តាមការកត់សម្គាល់ឃើញថាការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន ២ ៧៣១ ៣៣៨ហ.ត ស្មើនឹង១០៥,៦១% នៃផែនការ ២ ៥៨៦ ១៥២ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០១៩នេះ បានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វេទិកាសាធារណៈជាមួយក្រុមហ៊ុនសម្បទានដី-សេដ្ឋកិច្ច ការចូលរួមរៀបចំពិធីច្រត់ព្រះនង្គ័ល ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០១៩ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០១៩នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៩

#### ១.១ បញ្ចប់ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាមានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៨១៨ ៣២៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៣២ ៧៧៩ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧៨៥ ៥៤៤ហ.ត តិចជាងឆ្នាំមុនចំនួន ១៨៨ ២១៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ២៣ ១១៩ហ.ត តិចជាងឆ្នាំមុនចំនួន ១៣ ៨៥៤ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៣១ ៣៣៨ហ.ត ស្មើនឹង១០៥,៦១% នៃផែនការ ២ ៥៨៦ ១៥២ហ.ត តិចជាងឆ្នាំមុនចំនួន ៨ ១០៨ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវវស្សា

ការប្រមូលផលស្រូវសម្រេចបានចំនួន ២ ៥១៧ ២៦៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧ ៩១២ ០៤១តោន លើសឆ្នាំមុនចំនួន ៤៧៦ ៧៩៥តោន។ ទិន្នផលគិតជាមធ្យម ៣,១៤៣តោន/ហ.ត លើសឆ្នាំមុន៧១គ.ក្រ/ហ.ត។

### ២ លទ្ធផលផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៩-២០២០

#### ២.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០ (គិតត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩)

-ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៥៣៤ ០២៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២២៣ហ.ត និងដោយគ្រឿងយន្តមានចំនួន ៥២៩ ៨០១ហ.ត លើសឆ្នាំមុនចំនួន ៤០ ៩៨៤ហ.ត

-ផ្ទៃដីសាបសម្រេចបានចំនួន ៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ៨៨ហ.ត

-ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៥២៨ ១៣៦ហ.ត ស្មើនឹង១១៤,៩១% នៃផែនការ ៤៥៩ ៥៩៤ហ.ត លើសឆ្នាំមុនចំនួន ៥៤ ៣៩១ហ.ត។

### ២.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៩-២០២០

-ដំណាំរួមផ្សំអនុវត្តបានចំនួន ២៥ ២៤៩ហ.ត ស្មើនឹង៧៧,៩២% នៃផែនការ ៣២ ៤០៣ហ.ត លើសឆ្នាំមុនចំនួន ៤ ៨៨១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានចំនួន ៤៧ ៩១៩ហ.ត ស្មើនឹង៤៥,២៦% នៃផែនការ ១០៥ ៨៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ៨ ៦៨៦ហ.ត។

### ២.៣ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករក្នុងឆ្នាំ២០១៩ បានចំនួន ៦២០ ១០៦តោន មានការថយចុះចំនួន៦ ១១៩តោន (-0,៩%) តិចជាងបរិមាណនាំចេញក្នុងឆ្នាំ២០១៨ មានចំនួន៦២៦ ២២៥តោន និងបាននាំចេញទៅកាន់ទិសដៅចំនួន ៥៩ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (២៤៨ ១០៥តោន) ប្រទេសបារាំងលំដាប់ទី២ (៨១ ៩០៥តោន) ប្រទេសហ្កាបុងលំដាប់ទី៣ (៣៦ ៦៦៣តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (៣៦ ៣៩៧តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៥ (២៣ ៧៥០តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (២១ ៣៩០តោន) ប្រទេសប្រ៊ុយណេ លំដាប់ទី៧ (១៩ ៣៩៩តោន) ប្រទេសអង់គ្លេសលំដាប់ទី៨ (១៤ ៨៣៦តោន) ប្រទេសអេស្ប៉ាញ លំដាប់ទី៩ (១៣ ៨៧១តោន) និងប្រទេសប៊ែលហ្ស៊ិក ឈរលំដាប់ទី១០ (១២ ៨៧៦តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៨៩ក្រុមហ៊ុន។

## ៣ ផ្នែកកៅស៊ូ

### ៣.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្ត ប្រចាំឆ្នាំ (តោន) | បញ្ចេញលក់ ប្រចាំឆ្នាំ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៤២៧ | ២៩៥ |
| សរុប I | | ៦៧០ | ៨០១ | ៤២៧ | ២៩៥ |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ីនវេសមេនគ្រុប | ១២ ៧៨៨ | ១៥ ៦៥៧ | ១៥ ៩៥៥ | ១៦ ១៤៨ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ២២៦ | ២ ៤៤៦ | ១ ៦៥៩ | ១ ៧០១ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៦ ១០៣ | ៨ ០១៥ | ៤ ៥០១ | ៤ ៤៥០ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគិរី) | ២៤១ | ២ ៧២៤ | ៣៤៥ | ២៣៣ |
| ៥ | ក្រុមហ៊ុនស៊ីហ្វរីសសស៍លីមីធីត (ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៤ ៥១៤ | ៤ ៣០១ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេងអ៊ីនធើណេស៊ិនណល | ៣ ៩០៨ | ៤ ១៨៦ | ៣ ៨៨៩ | ៣ ៩៩២ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣១២ | ៤ ៨៨២ | ១ ៨២៤ | ១ ៥៧៧ |
| ៨ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៩១៨ | ៣ ០៣៧ | ១ ២៨៤ | ១ ១៥២ |
| ៩ | ក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌី | ៤ ៦៣៩ | ៤ ៧៩៨ | ៦ ១៤០ | ៦ ៥២២ |
| សរុបII | | ៣៧ ៩៩៤ | ៥០ ១៥១ | ៤០ ១១១ | ៤០ ០៧៦ |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧១ ៦១០ | ១៩៤ ០៨៨ | ៩៤៥០០ | ៩១៥០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១៣៦ ៨៣៩ | ១៦១ ១០២ | ១៥២៦០០ | ១៥០២០០ |
| សរុប III | | ២០៨ ៤៤៩ | ៣៥៥ ១៩០ | ២៤៧ ១០០ | ២៤១ ៧០០ |
| សរុប I + II + III | | ២៤៧ ១១៣ | ៤០៦ ១៤២ | ២៨៧ ៦៣៨ | ២៨២ ០៧១ |

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៦ ១៤២ហ.ត ផ្ទៃដីចៀរជ័រចំនួន ២៤៧ ១១៣ហ.ត ស្មើនឹង៦១%
- ផលិតផលជ័រកៅស៊ូក្នុងឆ្នាំ២០១៩ សម្រេចបានចំនួន ២៨៧ ៦៣៨តោន កើនឡើងចំនួន៦៧ ៥៣៨តោន ស្មើនឹង៣១% ធៀបនឹងឆ្នាំ២០១៨

- បរិមាណបញ្ចេញលក់ក្នុងឆ្នាំ២០១៩ សម្រេចបានចំនួន ២៨២ ០៧១តោន កើនឡើងចំនួន៦៤ ៥៧០តោន ស្មើនឹង៣០% ធៀបនឹងឆ្នាំ២០១៨

- គួរកត់សម្គាល់ថាក្នុងឆ្នាំ២០១៩នេះ ជ័រកៅស៊ូមានតម្លៃជាមធ្យម ១ ៣៣៦ដុល្លារ/តោន បានកើនឡើងចំនួន ១៩ដុល្លារ/តោន ស្មើនឹង១% ធៀបនឹងឆ្នាំ២០១៨។ ក្នុងខែធ្នូ ឆ្នាំ២០១៩ ជ័រកៅស៊ូមានតម្លៃជាមធ្យម ១ ៣៧១ដុល្លារ/តោន បានកើនឡើងចំនួន ៤៨ដុល្លារ/តោន ស្មើនឹង៣% ធៀបនឹងខែមុន។

### ៣.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមសន្និសីទកៅស៊ូអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ IRRDB នៅប្រទេសមីយ៉ាន់ម៉ា និងសិក្ខាសាលានៅប្រទេសម៉ាឡេស៊ី និងប្រទេសចិន

- វិភាគសរីរសាស្ត្រទឹកជ័រ (LD) លើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ d3 d4 និងប្រព័ន្ធចង្វាក់ចៀររង្វើល d3 d4 d5 និង d6

- វិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ (LD) លើប៉ារ៉ាមែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (RSH)

- ការពិសោធន៍សាកល្បងថ្នាំព្យាបាលជំងឺស្ងួតមុខចៀរ TPD Recovery និងការចៀរជ័រដោយម៉ាស៊ីន Tapping Machine ជាមួយអ្នកជំនាញការ CATAS និងពិភាក្សាការងារពិសោធន៍ស្រាវជ្រាវសម្រាប់ឆ្នាំបន្ទាប់

- បានផ្តល់ក្លូនកៅស៊ូចំនួន ១១ក្លូនទៅឱ្យ RRI-CATAS និងទទួលក្លូនចំនួន ១២ក្លូនពី RRI-CATAS

- រៀបចំបើកចៀរជ័រដំបូងចម្ការពិសោធន៍ IRAA10 លើផ្ទៃដីចំនួន ៦,០៦ហ.ត

- បាញ់ថ្នាំព្យាបាលជំងឺផ្កាកុលាប និងថែទាំកូនស្ទូមក្នុងបំពង់ជ័រ Root Trainer ក្លូន PMB1 ចំនួន ៧០០ដើម

- រៀបចំឯកសារមន្ទីរពិសោធន៍ជាតិយថាប្រភេទតម្រូវតាមស្តង់ដារ ISO/IEC: 17025: 2017

- ធ្វើការពិសោធន៍ស្រាវជ្រាវលើការបង្កកទឹកជ័រដោយប្រើប្រាស់អាស៊ីត៣ប្រភេទដែលមានកំហាប់ខុសៗគ្នា

- ចុះអង្កេតអំពីការប្រើប្រាស់ក្លូនកៅស៊ូក្នុងចម្ការនៅខេត្តរតនគិរី ស្ទឹងត្រែង ព្រះវិហារ សៀមរាប ឧត្តរមានជ័យ ប៉ៃលិន និងខេត្តពោធិ៍សាត់។

## ៤ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមធ្វើទស្សនកិច្ចនៅកសិដ្ឋានគោលដៅនៃកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅខេត្តកំពង់ឆ្នាំង

- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើវិស័យកសិកម្មកម្ពុជា-ថៃលើកទី៥

- បានចូលរួមកិច្ចប្រជុំស្តីពីការបង្កើតវេទិកានវានុវត្តន៍ដំណាំដំឡូងមី និងទិវាបង្ហាញគ្រឿងយន្តកសិកម្មសម្រាប់ការដាំដុះដំណាំដំឡូងមីនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា

- បានចូលរួមកិច្ចប្រជុំស្តីពីបទពិសោធន៍ និងវិធានការជាក់ស្តែងនៃការពុលមេតាណុលនៅខេត្តក្រចេះ

- បានរៀបចំសិក្ខាសាលាស្តីពីការអភិវឌ្ឍន៍កសិ-ឧស្សាហកម្មប្រកបដោយនិរន្តរភាព និងសុវត្ថិភាព

- បានរៀបចំ និងពិនិត្យឡើងវិញនូវវិធីសាស្ត្រសម្រាប់វិភាគរកសមាសធាតុអាស៊ូត (N) ផូស្វ័រ (P) និងប៉ូតាស្យូម (K) នៅក្នុងមន្ទីរពិសោធន៍ផលិតកម្មកសិកម្ម និងចំណីអាហារ

- ពិសោធន៍សាកល្បងលើការផ្សំអាហារបំប៉នសម្រាប់បណ្តុះមេផ្សិតម្ទល

- បានពិនិត្យ និងសិក្សាឡើងវិញលើឧបករណ៍វិភាគ DNA

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រថ្មីៗនៃការវិភាគរកគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ

- បានបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតផលកសិកម្មនៅខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តសៀមរាប

- បានបណ្តុះបណ្តាលកសិករស្តីពីការលើកកម្ពស់ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម

- បានចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការតាក់តែងនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់មន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា

- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម (AoA) និងកិច្ចព្រមព្រៀង SPS ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការជំរុញការនាំចេញផលិតផលកសិកម្មនៅខេត្តកំពត

- បានវិភាគរកសមាសធាតុ អាសូ៊ត និងផូស្វ័រនៅក្នុងដីកំប៉ុស្ត
- បានបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៃផលិតផលកសិកម្ម
- បានបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិ
- បានចុះសិក្សាស្វែងយល់ពីខ្សែច្រវាក់តម្លៃនៃស្វាយចន្ទីកែច្នៃរបស់ក្រុមហ៊ុន SANTANA
- បានចុះហត្ថលេខាផលិតកម្មកសិកម្មតាមកិច្ចសន្យាស្តីពីការផលិត និងផ្គត់ផ្គង់ស្រូវសរីរាង្គតាមស្តង់ដារអន្តរជាតិ (អឺរ៉ុប-អាមេរិក) រវាងក្រុមហ៊ុនសាជីវកម្មសហគមន៍កសិកម្មកម្ពុជា និងសហគមន៍កសិកម្មចំនួន៦
- បានរៀបចំសិក្ខាសាលាស្តីពីការវិនិយោគអាជីវកម្មប្រកបដោយបរិយាប័ន្នក្នុងកសិ-ធុរកិច្ច
- បានចូលរួមសន្និសីទអន្តរជាតិលើកទី១ស្តីពីទេសចរណ៍ម្ហូបអាហារកម្ពុជាក្រោមប្រធានបទលើកកម្ពស់គុណតម្លៃប្រពៃណី និងបេតិកភ័ណ្ឌដើម្បីអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានចេញប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ១១កន្លែងមានផ្ទៃដីសរុបទំហំ ៧ ៣៤៩,៩៥ហ.ត ក្នុងនោះខេត្តកំពង់ធំចំនួន ១កន្លែងមានផ្ទៃដីទំហំ ១ ២៧៥,៤៦ហ.ត និងខេត្តបាត់ដំបងចំនួន ១០កន្លែងមានផ្ទៃដីទំហំ ៦ ០៧៤,៤៩ហ.ត
- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ១២កន្លែងមានផ្ទៃដីទំហំ ៧ ៥០១,៤៩ហ.ត ក្នុងខេត្តមណ្ឌលគិរីចំនួន ១កន្លែងមានផ្ទៃដីទំហំ ១ ១០៤ហ.ត ខេត្តបាត់ដំបងចំនួន ១០កន្លែងមានផ្ទៃដីទំហំ ៦ ០៧៤,៤៩ហ.ត និងខេត្តកោះកុងចំនួន ១កន្លែងមានផ្ទៃដីទំហំ ៣២៣ហ.ត
- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៧១គ្រឿង និងយានយន្តចំនួន ១០៧គ្រឿងជូនក្រុមហ៊ុនចំនួន៦ និងអ្នកស្នើសុំចំនួន៣នាក់
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន១៣ និងអ្នកស្នើសុំចំនួន៥ដែលមានឈើហ៊ុបមូលចំនួន៣៣ ១០៣ម៣ ឈើអារចំនួន ៤ ១៨៤ម៣ ឈើប្រណីតចំនួន១០៨ម៣ និង ៧៤៣គ.ក្រ ឈើជ្រុងចំនួន ២ ៧៩០ម៣ កូនឈើចំនួន ២០០ ០១៨ដើម អុសចម្រុះចំនួន ៥៣ ១៨១ស្ទែរ ជន្លង់ម្រេចចំនួន២៣៩ដើម សសរចំនួន ៥៦ដើម ធ្យូងចំនួន១៨ ២១៧គ.ក្រ គ្រាប់ស្លែងចំនួន៥៣៧គ.ក្រ គល់ធ្នង់ និងគល់បេងចំនួន៥៩០គ.ក្រ ពកបេងចំនួន ៣៩៤គ.ក្រ និងជ័រទឹកចំនួន៤៨២តោន និងបានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើសាជាថ្មីជូនក្រុមហ៊ុន ឈុន ហុង ក្រុមហ៊ុនទ្រីភាព និងអ្នកស្នើសុំមានលោក អ៊ឹង ឃ្លូ លោក យ៉េង យ៉ន លោក ជន សុរិន។

### ៥.២ ការងារដាំដើមឈើ

- ថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូត៍បង្ហាញកសិ-រុក្ខកម្មចំនួន ៩៨០ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៤ទីតាំង ស្ថិតក្នុងខេត្តកំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តស្វាយរៀង
- បានថែទាំចម្ការរុក្ខទិវាសរុបចំនួន ៦០ហ.ត ស្ថិតនៅក្នុងខេត្តកំពត កណ្តាល តាកែវ កំពង់ធំ និងខេត្តក្រចេះ
- បានរៀបចំពិធីរុក្ខទិវាថ្នាក់ជាតិ ០៩កក្កដា ឆ្នាំ២០១៩ ដែលប្រារព្ធឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ លើផ្ទៃដីទំហំ ១០ហ.ត ដែលបានដាំកូនកកោះ គគីរ ធ្នង់ អង្កាញ់ និងក្រញូងចំនួន ១០ ៦៩៥ដើម ព្រមទាំងបានបោះបង្គោលថ្ម និងព័ទ្ធរបងលួសប្រវែង ១ ៥០០ម៉ែត្រ
- បានបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្មក្នុងសហគមន៍ចំបក់ហោះស្ថិតនៅស្រុករវៀង ខេត្តព្រះវិហារ និងបានដាំរួចលើផ្ទៃដីទំហំ ១២ហ.ត គ្រប់ចំនួនតាមផែនការប្រចាំឆ្នាំ២០១៩ មានដំណាំកសិកម្ម (កូនស្វាយចន្ទីចំនួន ២ ៥០០ដើម ចេកចំនួន ១ ៣៥០ដើម និងកូនឈើប្រភេទក្រញូង បេង និងធ្នង់ចំនួន ២ ៧០០ដើម)។

### ៥.៣ ការងារអភិរក្សសត្វព្រៃ

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ១០លើក នៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ កោះកុង និងរតនគិរីដោយបានរឹបអូសសាច់សត្វជ្រូកព្រៃចំនួន ៩៦គ.ត សាច់សត្វឈ្លូសចំនួន ២៩គ.ត រណាយន្តចំនួន ២គ្រឿង ដោះអន្ទាក់ចំនួន ៣០ខ្សែ ជ្រូកព្រៃ១ក្បាលងាប់ដោយជាប់អន្ទាក់ សត្វត្រកួតរស់ចំនួន ១៥ ក្បាល សត្វអន្សង់រស់ចំនួន ២ក្បាល និងអណ្តើករស់ចំនួន ៨ក្បាល
- ចុះផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃចំនួន ៤លើកនៅខេត្តមណ្ឌលគិរី កំពង់ធំ ពោធិ៍សាត់ និងខេត្តក្រចេះ ដោយមានអ្នកចូលរួមសរុបចំនួន ៤៥០នាក់ និងបានចែកផ្ទាំងរូបភាពអប់រំចំនួន ៤៥០ សន្លឹក និងអាវយឺតចំនួន ៤៥០អាវ

- បានផ្តល់លិខិតអនុញ្ញាតថែរក្សាសត្វក្រចៀកកាំជាលក្ខណៈគ្រួសារចំនួន ៤១ច្បាប់ ក្នុងនោះ៣០ច្បាប់សម្រាប់ថែរក្សាសត្វក្រចៀកកាំ និង១១ច្បាប់ទៀតសម្រាប់ថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតមាន ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម ព្រៃវែង កំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ កោះកុង តាកែវ សៀមរាប បន្ទាយមានជ័យ រតនគិរី និងខេត្តមណ្ឌលគិរី។

### ៥.៤ បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- កសិដ្ឋានចំនួន ៦កន្លែង បានថែរក្សា និងបង្កាត់ពូជស្វាក្តាមសរុបចំនួន ៥៣ ២១៣ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ១៥ ៦៩៧ក្បាល

- បានចុះត្រួតពិនិត្យកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាម និងជំរុញការចុះបញ្ជីថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ២៩លើក ត្រូវជា ២៦២ទីតាំង នៅខេត្តចំនួន ២០ក្នុងនោះ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កំពត ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង សៀមរាប ព្រះវិហារ កំពង់ធំ រតនគិរី បាត់ដំបង កែប ក្រចេះ ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តតាកែវ

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៤៨៦ក្បាល (បក្សីចំនួន ៥៣ប្រភេទ ថនិកសត្វចំនួន ៤១ប្រភេទ និងល្មូនចំនួន ១៣ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ១០៥ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២៧០ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ១ ២៧៥ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ដោះលែងក្រពើភ្នំពូជសុទ្ធចំនួន ២០ក្បាលទៅក្នុងដែនជម្រកធម្មជាតិនៅស្ទឹងខៀវ ខេត្តកោះកុង និងតាមដានប្រចាំឆ្នាំវត្តមានក្រពើភ្នំតាមវិធីសាស្ត្រពំនុះកាត់ទទឹងដែនជម្រកនៅតំបន់ឆាយរាប អូរសោម ស្ទឹងដាច់ ដំណាក់ត្នួងស្ទឹងអារ៉ែង ស្ទឹងខៀវ បានរកឃើញលាមកក្រពើភ្នំចំនួន ៩៣ដុំ ដានជើងចំនួន ៤២កន្លែង និងឃើញក្រពើផ្ទាល់ចំនួន ១២ក្បាល និងបានតាមដានក្រពើភ្នំដែលបានដោះលែងក្នុងឆ្នាំ២០១៨ តាមរយៈ Radio tracking ដោយបានរកឃើញក្រពើភ្នំលែងចំនួន ៧ក្បាល និងស្នាមដាន ១កន្លែង

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមចំនួន ១៥ ១០៦ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៥២ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៥.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១ ២០១ករណី ដោយពិន័យអន្តរការណ៍ចំនួន ៥៩៨ករណី និងបញ្ជូនទៅតុលាការចំនួន ៦០៣ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ៣៩៧ម៣ ឈើអារសរុបចំនួន ២ ៩៦៧ម៣ ឈើគ្រាក់ក្រញូង ២ម៣ សត្វព្រៃចម្រុះប្រភេទសរុបចំនួន ៤ ៤៨១ ក្បាល និង ៨៧៦,៨០គ.ក្រ ផ្ទៃដីព្រៃបានកាប់រានទំហំ ១ ៧៧៣ហ.ត នៅខេត្តកំពង់ឆ្នាំង ក្រចេះ ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កំពង់ស្ពឺ ព្រះសីហនុ ពោធិ៍សាត់ និងខេត្តបាត់ដំបង និងអនុផលព្រៃឈើ ព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត

- បានផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងព្រៃឈើចំនួន ៣៨លើក នៅខេត្តកំពង់ស្ពឺ កោះកុង កែប បន្ទាយមានជ័យ ឧត្តរមានជ័យ ក្រចេះ មណ្ឌលគិរី កំពត តាកែវ ស្ទឹងត្រែង រតនគិរី កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំដែលមានអ្នកចូលរួមសរុបចំនួន ១ ៤៦៣នាក់(ស្ត្រី៥៦៦នាក់) និងចែកឯកសារចំនួន ៨៣០ច្បាប់។

### ៥.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានពិនិត្យបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន១០ក្រុមហ៊ុន ស្មើនឹង១០កន្លែង

- បានពិនិត្យពន្យារសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើមានចំនួន១៩ក្រុមហ៊ុន ស្មើនឹង២២កន្លែង

- បានចុះសិក្សាអត្រាកែច្នៃកូនឈើអង្កត់ផ្ចិតទំហំ១៥-៣០ស.ម ចំនួន៥ក្រុមហ៊ុន ស្មើនឹង៦កន្លែង

- បាននាំចេញផលិតផលរានទេវតា គ្រឿងសង្ហារិម ជើងសាឡុង និងឈើអារកែច្នៃ (ទោល-បន្ទារអតិបរមា២៥ស.ម) ទៅក្រៅប្រទេស (ជប៉ុន អាមេរិក ចិន វៀតណាម និងថៃ) មានបរិមាណចំនួន២ ១៧៨ម³ និងជ័រទឹកចំនួន២៩១តោន ដោយក្រុមហ៊ុនចំនួន៧

- បាននាំចូលផលិតផលប្រភេទឈើ MDF, Wood Panel, CHANFUTA, (ពីប្រទេសចិន កុងហ្គោ កាមេរូន និងអ៊ូហ្គង់ដា) និងឈើកែច្នៃមានបរិមាណចំនួន១ ៦៨១ម³ ដោយក្រុមហ៊ុនចំនួន៤

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១៣ មានបរិមាណផលិតផលឈើកែច្នៃ (ទោល-បន្ទារអតិបរមា២៥ស.ម) ប្រភេទលេខ១ ក្តារការ៉ូក្រាល គ្រឿងសង្ហារឹម និងជើងសាឡុងចំនួន២ ៨៣០ម³ ឈើអាកាស្យាកាត់ជាកង់ៗចំនួន១ ៦៣២ស្ទែរ និងអនុផលព្រៃឈើ (ជ័រទឹក សង្ហារិមឬស្សីកែច្នៃ និងឈើចន្ទន៍ក្រស្នាកែច្នៃ) ចំនួន២៦៨តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៤ មានបរិមាណផលិតផលឈើកែច្នៃ (Wood Panel, CHANFUTA, MDF, DOUSSIE និង MUSSIVI) ចំនួន១ ៧៥២ម³ ។

### ៥.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារព្រៃឈើសរុបចំនួន ២៥ ៧២៩ ១៦៧ ៤៨៥រៀល និង១៤៨ ២៨១,៧០ដុល្លារ។

## ៦ ផ្នែកផលិតកម្ម និងបសុពេទ្យាបាល

**៦.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ងួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៦.២ ការងារបសុពេទ្យាបាល

- **លទ្ធផលត្រួតពិនិត្យ បង្ក្រាបបទល្មើសសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖** នៅរាជធានី-ខេត្តចំនួន២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ២៣៤ ៦២៥លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសរុបចំនួន ៤១០ករណី ក្នុងនោះឃាត់ចាប់ចំនួន ៦២ករណី និងត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ៣៤៨ករណី។
- **ការងារសុខភាពសាធារណៈ៖** បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌នៅតាមខេត្តចំនួន៦ ចុះបង្កើនការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសនៅខេត្តចំនួន៨ ចុះវាយតម្លៃការស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋាននៅខេត្តបាត់ដំបង សៀមរាប និងខេត្តបន្ទាយមានជ័យ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះអប់រំផ្សព្វផ្សាយជំងឺឆ្លងសត្វនៅតាមខេត្តចំនួន១៤ ចុះបណ្តុះបណ្តាលបច្ចេក-ទេសចិញ្ចឹមសត្វ និងដាំដំណាំចំណីសត្វនៅតាមខេត្តចំនួន១៤ ចុះប្រជុំណែនាំជំងឺប៉េស្តជ្រូកអាហ្វ្រិច និងបច្ចេកទេសចិញ្ចឹមសត្វនៅតាមខេត្តចំនួន១៥។
- **ការងារនីតិកម្មនិងវិវាទ៖** ចុះប្រជុំផ្សព្វផ្សាយស្តីពីនីតិវិធីនៃការចុះបញ្ជីចំណីសត្វ បសុឱសថ ក្រុមហ៊ុន សហគ្រាស រៀបចំសិក្ខាសាលាចំនួន៣លើក ចុះផ្សព្វផ្សាយច្បាប់ស្តីពីអាជីវកម្ម និងចែកជូនលិខិតអនុញ្ញាតច្បាប់សម្រាប់ឆ្នាំ២០១៩ ដល់អាជីវករពិឃាតសត្វនៅតាមខេត្តចំនួន២។

### ៦.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៣ក្បាល ក្នុងនោះកូនគោកើតចំនួន ៩ក្បាល បង្កាត់មេគោរកឈ្មោលចំនួន ១១ក្បាល និងបានលក់គោចំនួន ៦ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ៦៥៨ក្បាល។



៩៤

• ការងារស្រាវជ្រាវបសុព្យាបាលៈ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១៨ ៤០៩វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺប៉េស្តជ្រូកអាហ្វ្រិកផ្ទុះចំនួន ៦ខេត្ត នៅខេត្តរតនគិរី ត្បូងឃ្មុំ ស្វាយរៀង កណ្តាល និងខេត្តតាកែវ។

## ៧ ផ្នែកជលផល

### ៧.១ អាជីវកម្មនេសាទ

#### ៧.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តចំនួន ១៤ ៣២០តោន ស្មើនឹង១១៩,៣៣% នៃផែនការ១២ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ២ ៦៥៥តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តចំនួន ៣២៦ ៥០០តោន ស្មើនឹង៩៤,៦៤% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ៣៤ ២៣០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១៣៨ ០៣០តោន ស្មើនឹង៩៥,១៩% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ១៩ ២៧០តោន។

#### ៧.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១២២ ២៥០តោន ស្មើនឹង១១១,១៤% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ កើនឡើងចំនួន ១ ១៥០តោន។

### ៧.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៣០៧ ៤០៨តោន ស្មើនឹង១០២,៤៧% នៃផែនការ ៣០០ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ កើនឡើងចំនួន ៥៣ ៣៦០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៤១២ ៨១១ក្បាល ស្មើនឹង១៣៧,៦០% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបឆ្នាំ២០១៨ កើនឡើងចំនួន ២ ៨១១ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២២១ ៤០០ ០០០កូន ស្មើនឹង៩២,២៥% នៃផែនការ ២៤០ ០០០ ០០០កូន ប្រៀបធៀបឆ្នាំ២០១៨ កើនឡើងចំនួនប្រមាណ ១១ ៤០០ ០០០កូន។

### ៧.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៧២ ០៧៥តោន ស្មើនឹង៨៧,៩០% នៃផែនការ៨២ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ៩២៥តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៧ ១០៥តោន ស្មើនឹង៧៨,៩៤% នៃផែនការ ៩ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ៣ ៦៣០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤៥ ០០០ ០០០លីត្រ ស្មើនឹង៨១,៨២% នៃផែនការ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ១៣ ០០០ ០០០លីត្រ។

### ៧.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៣ ១០១ករណី ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ១០៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២ ៨៧៣ករណី និងសមុទ្រចំនួន ២២៨ករណី។

### ៧.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ៩ ១៩០តោន ស្មើនឹង៦១,២៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ៣១០តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ៤ ៩១០តោន ស្មើនឹង៩៨,២០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៨ ថយចុះចំនួន ៩០តោន។

## ៨ ផ្នែកអគ្គាធិការដ្ឋាន

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង និងខេត្តកំពង់ស្ពឺ

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ ការគ្រប់គ្រង និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនត្រូវកែលម្អរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ កំពង់ឆ្នាំង កណ្តាល ព្រៃវែង ស្វាយរៀង ឧត្តរមានជ័យ តាកែវ រតនគិរី ស្ទឹងត្រែង ក្រចេះ កែប កំពត មណ្ឌលគិរី និងខេត្តតាកែវ

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលសៀមរាប ពិនិត្យស្ថានភាពនៃការធ្វើវារីវប្បកម្មក្រពើ និងតម្លៃកូនក្រពើនៅខេត្តសៀមរាប

- ចុះជួបពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈភិបាលខេត្តកំពង់ស្ពឺ និងលោកប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺអំពីការនាំចេញផ្លែស្វាយពីប្រទេសកម្ពុជាទៅកាន់បរទេស

- ចុះបង្ក្រាបការកាប់ទន្ទ្រានព្រៃលិចទឹក និងបង្ក្រាបបទល្មើសនេសាទខេត្តកំពង់ធំ

- ចុះជួបពិភាក្សាជាមួយអាជ្ញាធរខេត្តដើម្បីប្រមូលព័ត៌មានជាក់ស្តែងដល់ទីតាំងបានកាប់បំផ្លាញចម្ការអាកាស្យា និងធ្វើផ្លូវកាត់តំបន់វិនិយោគគម្រោងសម្បទានដីសេដ្ឋកិច្ចខេត្តកោះកុង

- ចុះពិនិត្យទីតាំងចិញ្ចឹមជ្រូកនៅស្រុករមាសហែក និងស្រុកផ្សេងទៀតក្នុងខេត្តស្វាយរៀង

- ចុះពិនិត្យទីសត្តឃាតដ្ឋាន និងកន្លែងពិឃាតក្នុងភូមិសាស្ត្រខេត្តកណ្តាល

- ចូលរួមពិនិត្យការជីកស្រះស្តុបទឹកក្នុងការប្រើប្រាស់ក្នុងការងារស្រាវជ្រាវកសិកម្មរបស់វិទ្យាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានទទួលពាក្យបណ្តឹងចំនួន ៣ករណី ក្នុងនោះពាក្យបណ្តឹងអនាមិកចំនួន ២ករណី

- បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមានអ្នកចូលរួមចំនួន ១២៧នាក់ និងចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ១៣៤លើក។

## ៩ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចុះប្រមូលសំណាកផ្កាអ័រគីដេ និងដំណាំផ្សេងទៀតចំនួន ១៩៧សំណាក និងបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទរួមមានស្រូវចំនួន ៦,៧៣១បញ្ជិក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទសរុបចំនួន ២ ២៧៨បញ្ជិក/សំណាក សរុបទាំងអស់ចំនួន ៩ ០០៩បញ្ជិក/សំណាក។ ដាំវាយតម្លៃនិងកំណត់លក្ខណៈសំណាកត្រសក់ស្រូវ ម្ទេស ល្ពៅ និងសណ្តែកព្រៃចំនួន៥៣, ៥៨, ២៤ និង៤៣សំណាករៀងគ្នា និងកំពុងរៀបចំចងក្រងសៀវភៅលក្ខណៈប្រភេទពូជ (Catalog) ពីរច្បាប់សម្រាប់ពូជម្ទេស និងត្រសក់ស្រូវ

- បានធ្វើពិសោធន៍ចំនួន ៩៤ប្រភេទនៅ ៦៥៥កន្លែង ដែលនៅក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៤៣៩កន្លែង ធ្វើការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសចំនួន ៥វគ្គ មានអ្នកចូលរួមសរុបចំនួន ១៥១នាក់ ធ្វើការបណ្តុះបណ្តាលកសិករចំនួន ៤០ដងជូនដល់កសិករចំនួន ១ ៦៣៥នាក់(ស្ត្រី៥៥%) និងធ្វើទិវាស្រែចំនួន ៨លើក មានកសិករចូលរួម ៣៧៦នាក់ (ស្ត្រី៥១%)

- បានបញ្ចេញប្រភេទពូជស្រូវចំនួន ១ពូជជាឯកត្តៈជម្រើសចេញពីក្រុមប្រភេទពូជសែនក្រអូប ហើយគណៈកម្មការបញ្ចេញប្រភេទពូជដំណាំដាក់ឈ្មោះថា សែនក្រអូប០១។ សែនក្រអូប០១ ជាប្រភេទពូជស្រូវស្រាលមិនប្រកាន់រដូវមានអាយុកាលជាមធ្យម ១០៥ថ្ងៃ(ព្រោះ) និង ១១៥ថ្ងៃ(ស្ទូង) គ្រាប់អង្ករសថ្លាមានបណ្តោយ ៧,១៥មម បន្ទារ ១,៩៥មម អាមីឡូស១៦% ផ្តល់ទិន្នផលមធ្យម ៣,៩ត/ហត និងអាចដល់ ៥,៨ត/ហត ហើយមានក្លិនក្រអូបស្រាល។ ពូជស្រូវនេះមិនមានលក្ខណៈធន់ទ្រាំទៅនឹងជំងឺ និងសត្វល្អិតចង្រៃឡើយ។ ទន្ទឹមនឹងនេះ បានជំរុញការទទួលយកប្រភេទពូជស្រូវថ្មី ផ្កាមាលតី និងដំណើបស្បៃមង្គល តាមរយៈការធ្វើស្រែបង្ហាញជាមួយកសិករ ១០០កន្លែង/មួយពូជ និងយកអង្ករដំណើបស្បៃមង្គលដាក់លក់ផ្សព្វផ្សាយនៅផ្សារទំនើបឡាក់គីមួយចំនួន

- បានបង្កើតផែនទីក្រុមដីដាំដុះស្រូវចំនួន ២ស្រុក គឺស្រុកបាភ្នំ និងតាំងគោកហើយបានសិក្សារកឃើញបច្ចេកវិទ្យាគ្រប់គ្រងដំណាំចំនួន៨ និងលទ្ធផលអង្កេតសង្គមសេដ្ឋកិច្ចមួយចំនួន

- បោះពុម្ពឯកសារចំនួន ៣០ ៣៤០ច្បាប់ និងបែងចែកឯកសារសរុបចំនួន ១៩ ៨៣៣ច្បាប់ និងអត្ថបទវិទ្យាសាស្ត្រចំនួន ២អត្ថបទ។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានកាឌីតាមរយៈគេហទំព័រ http://www.cardi.org.kh ចំនួនសរុប ១ ០៥៧ ៣៨៣នាក់ គិតជាមធ្យមចំនួន ២ ៩០៥នាក់/ថ្ងៃ លើសឆ្នាំ២០១៨ ចំនួន ២៧៤នាក់/ថ្ងៃ

- បានចែកគ្រាប់ពូជស្រូវជូនកសិករចំនួន ៣៤០គ្រួសារនៅខេត្តត្បូងឃ្មុំ ឧត្តរមានជ័យ តាកែវ និងព្រៃវែងសរុប ១ ៧០០គ.ក្រ សម្រាប់ផលិតក្នុងរដូវវស្សា និងរដូវទឹកស្រកឆ្នាំនេះទុកជាគ្រាប់ពូជសម្រាប់ប្រើប្រាស់ឆ្នាំបន្ទាប់ ដោយក្នុងរដូវវស្សានេះ កសិករចំនួន ២១០គ្រួសារនៅខេត្តត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យផលិតបានគ្រាប់ពូជសរុបចំនួន ៣៣តោន។ ផលិតគ្រាប់

ពូជស្រូវគ្រឹះ ចុះបញ្ជី និងវិញ្ញាបនបត្របានប្រមាណ ៦៤តោន។ ទន្ទឹមនឹងនេះបានលក់ និងចែកចាយដល់អ្នកប្រើប្រាស់នូវគ្រាប់ពូជស្រូវជាង ១៣តោន

- បានចូលរួមសន្និបាតនិងកិច្ចប្រជុំនានានៅក្នុងនិងក្រៅប្រទេសចំនួន ៨២លើក និងទទួលជួបភ្ញៀវជាតិ-អន្តរជាតិនៅវិទ្យាស្ថានចំនួន ១៨លើកដែលមានភ្ញៀវសរុបចំនួន ៥០នាក់។

## ១០ ផ្នែកនីតិកម្មកសិកម្ម

### ១០.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម ជីកសិកម្មចំនួន ២៣៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២២៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតនាំចេញចំនួន ២ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មបានចំនួន ៧៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១១ក្រុមហ៊ុន។

### ១០.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ១០០ក្រុមហ៊ុន សរុបចំនួន ៧៣៧សំណាក។

### ១០.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តកំពត តាកែវ កំពង់ស្ពឺ រតនគិរី ស្ទឹងត្រែង បន្ទាយមានជ័យ ក្រចេះ ឧត្តរមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ មណ្ឌលគិរី ពោធិ៍សាត់ និងបាត់ដំបង ដែលមានអ្នកចូលរួមចំនួន ៨៤៦នាក់។

## ១១ ផ្នែករដ្ឋបាល

- ក្នុងឆ្នាំ២០១៩នេះ បានទទួលលិខិតសរុបចំនួន ១០ ១១៩ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៤ ១៦០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៤ ១០៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ៨៥៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១៣ ៥៧២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរណែនាំចំនួន ៥៥៦ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២១៨ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១២ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៦ ៦០១នាក់ (ស្រី១ ៥៦៩នាក់ ស្មើនឹង២៣,៧៦%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៤៨នាក់ (ស្រី៨១២នាក់) ស្មើនឹង២៨,៥១%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ៧៥៣នាក់ (ស្រី៧៥៧នាក់) ស្មើនឹង២០,១៧%
- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៤២៣នាក់ (ស្រី១១៧នាក់)

- បានចេញប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៤៦នាក់ (ស្រី១១នាក់) ក្នុងនោះ បោះបង់ចោលការងារចំនួន ១៣នាក់ លាឈប់ពីការងារចំនួន ១៤នាក់ និងមរណភាពចំនួន ១៩នាក់

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៦នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន ១៤នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន ២៦នាក់

- បានចេញប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំនួន ៩នាក់

- ចេញប្រកាសអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញបន្ទាប់ពីស្ថិតនៅក្រៅក្របខ័ណ្ឌដើមចំនួន ២នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ១៤២នាក់ (ស្រី៨០នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៦៣នាក់ ច្បាប់រយៈពេលខ្លីចំនួន ៦នាក់ ច្បាប់ពិសេសចំនួន ២នាក់ ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ៦នាក់ ច្បាប់មានធុរៈផ្ទាល់ខ្លួនចំនួន ១០នាក់ និងច្បាប់សម្រាកមាតុភាពចំនួន ៥៥នាក់

- បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៥៩នាក់

- បានចេញប្រកាសឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញចំនួន ៣៦នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន២ ២៦៨នាក់ (ស្រី៤៩៧នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១ ៣៥២នាក់ (ស្រី៣០៥នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៩១៦នាក់ (ស្រី១៩២នាក់)។

## ១៣ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី)

- បានរចនា និងបង្កើតទម្រង់គេហទំព័រ និងកម្មវិធីស្មាតហ្វូនថ្មីៗបន្ថែមទៀតលើ Mobile App (iOS & Android Platform)

- បានបង្កើតមុខងារថ្មីៗដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មានលើគេហទំព័រ និងកម្មវិធីស្មាតហ្វូន

- បានបញ្ចូលព័ត៌មាន និងរៀបចំឲ្យទាញយកកម្មវិធីប្រើប្រាស់នៅលើ App Store និង Play Store

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្តុះបណ្តាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១៣ ដូចជា៖ ខេត្តប៉ៃលិន ឧត្តរមានជ័យ កំពង់ឆ្នាំង បាត់ដំបង ព្រះវិហារ ពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពត និងខេត្តកែប

- បន្តរៀបចំកសាងគេហទំព័រព័ត៌មានភូមិសាស្រ្តកសិកម្ម ដោយបានរៀបចំកាត់ផែនទីចំនួន១៣ខេត្ត ដូចជា៖ ខេត្តស្វាយរៀង ព្រៃវែង ពោធិ៍សាត់ កែប ព្រះសីហនុ ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង ប៉ៃលិន មណ្ឌលគិរី កំពង់ស្ពឺ កោះកុង និងខេត្តបន្ទាយមានជ័យ និងរៀបចំបង្កើតទំព័រគ្រប់គ្រងទិន្នន័យគ្រោះមហន្តរាយ

- ចុះធ្វើការបណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្រ្តកសិកម្មប្រព័ន្ធទូរស័ព្ទដៃឆ្លាតវៃក្នុងចុះការប្រមូលទិន្នន័យ និងប្រមូលចងក្រងទិន្នន័យគ្រោះមហន្តរាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន១២ ដូចជា៖ ខេត្តស្វាយរៀង ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី កណ្តាល កំពង់ស្ពឺ កែប ព្រះសីហនុ កោះកុង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ

- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ គឺបច្ចេកវិទ្យាព័ត៌មានផ្សារភ្ជាប់នឹងវិស័យកសិកម្ម វឌ្ឍនភាពនៃការប្រើប្រាស់គេហទំព័របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យកសិកម្ម។

## ១៤ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១៨ ធ្វើការបែងចែកសម្ភារការិយាល័យ សង្ហារិមសម្ភារបរិក្ខាបច្ចេកទេស ថែទាំ ជួសជុល និងផ្គត់ផ្គង់

- រៀបចំផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ ផែនការថវិកាឆ្នាំ២០២០ និងផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២០

- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 M2

- បានចុះធ្វើសវនកម្មចំនួន ៤៧សវនដ្ឋាន ស្មើនឹង៩៥,៩១% នៃផែនការ៤៩សវនដ្ឋាន និងផ្តល់អនុសាសន៍កែលម្អចំនួន ៣១៥អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០,៦៦% នៃផែនការចំនួន៥០%។

## ១៥ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំបញ្ជូនគម្រោងកម្មវិធីវិនិយោគសាធារណៈ (កវស) ៣ឆ្នាំរំកិល ឆ្នាំ២០២០-២០២២ ជូនក្រសួងផែនការតាមអនឡាញ និងHard Copy ដែលមានគម្រោងសរុបចំនួន ៦៦គម្រោង

- បានរៀបចំធាតុចូលសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៨-២០២៣ និងឆ្នាំ២០១៩-២០២៣

- អនុញ្ញាតជាគោលការណ៍ផ្លាស់ប្តូរស្រូវពូជចាស់យកស្រូវពូជថ្មីផ្តល់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលចំនួន ២០ ៧៣៤គ.ក្រ

- អនុញ្ញាតជាគោលការណ៍ផ្លាស់ប្តូរស្រូវពូជចាស់យកស្រូវពូជថ្មីផ្តល់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់ចំនួន ១ ៤៧១គ.ក្រ

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្និធិស្រូវពូជក្រោយពេលដោះដូរ ដើម្បីត្រៀមទុកប្រើពេលមានគ្រោះធម្មជាតិឆ្នាំ២០១៩ នៅខេត្តមណ្ឌលគិរី តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង

- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត

- បានចុះពិនិត្យតាមដានអំពីការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មខេត្តក្រចេះ ស្ទឹងត្រែង កំពង់ចាម ត្បូងឃ្មុំ កំពង់ស្ពឺ កោះកុង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កែប ព្រះសីហនុ សៀមរាប បន្ទាយមានជ័យ តាកែវ កំពត ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង ប៉ៃលិន ព្រះវិហារ ឧត្តរមានជ័យ កំពង់ធំ និងខេត្តកណ្តាល

- បានរៀបចំការស្ទង់ចុះអង្កេតទិន្នផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៩-២០២០

- រៀបចំសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣

- រៀបចំសិក្ខាសាលាស្តីពីបច្ចេកវិទ្យាព័ត៌មានលើការប្រមូល និងប្រើប្រាស់ទិន្នន័យសម្រាប់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងកសិកម្ម។

## ១៦ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- សម្របសម្រួលលើការចុះហត្ថលេខាបន្តសុពលភាពលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ាន-ចិនលើវិស័យអនាម័យ និងភូតគាមអនាម័យ

- សម្របសម្រួលធ្វើលិខិតស្នើសុំគោលការណ៍បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅចូលរួមកិច្ចប្រជុំក្រុមការងារអាស៊ានស្ថិតក្រោមរចនាសម្ព័ន្ធកិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យស្បៀង កសិកម្ម និងព្រៃឈើនៅក្រៅប្រទេស

- សម្របសម្រួលស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលដើម្បីទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី៤២

- សម្របសម្រួលលិខិតជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈប្រតិភូចូលរួមទស្សនកិច្ចនៅវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិនៅប្រទេសហ្វីលីពីន

- សម្របសម្រួលករណីសុំគោលការណ៍អញ្ជើញឯកឧត្តមរដ្ឋមន្ត្រីដើម្បីចូលរួមក្នុងទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងវាលខ្សាច់ឆ្នាំ២០១៩ និងខួបលើកទី២៥ នៃ UNCCD នៅទីក្រុង Ankara ប្រទេសតួកគី

- សម្របសម្រួល និងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម (AoA) កិច្ចព្រមព្រៀង SPS ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការជំរុញការនាំចេញផលិតផលកសិកម្មនៅខេត្តកំពត

- សម្របសម្រួលលិខិតទៅក្រសួងពាណិជ្ជកម្មដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមច្រកព្រំដែនកម្ពុជា វៀតណាម

- សម្របសម្រួលលើកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ ADRA ស្តីពីការលើកកម្ពស់ខ្សែច្រវាក់ផលិតកម្មទីផ្សារតាមរយៈនិរន្តរភាពផលិតកម្មកសិកម្ម។

## ១៧ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៧.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៣ ០៥២នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានដំណើរការវគ្គបណ្តុះបណ្តាលដោយជោគជ័យ ស្តីពីបច្ចេកទេសកែច្នៃនិងវេចខ្ចប់ផលិតផលកសិកម្ម

- បានរៀបចំសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងឧត្តមសិក្សាកសិកម្ម ជូនថ្នាក់ដឹកនាំនិងមន្ត្រីសាស្ត្រាចារ្យ

នៃសាកលវិទ្យាល័យភូមិន្ទកសិកម្មទាំងមូល ដោយមានកិច្ចសហការជាមួយធនាគារពិភពលោកក្នុងគម្រោងពង្រឹងគុណភាពឧត្តមសិក្សា របស់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា

- បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាជីវឧស្ម័នជូនដល់សមាជិក សមាជិកា នៃមជ្ឈមណ្ឌលបច្ចេកវិទ្យានិងព័ត៌មានជីវឧស្ម័នខ្នាតធំ ជាពិសេសការស្រាវជ្រាវកែច្នៃម៉ាស៊ីនប្រើប្រាស់សាំងឱ្យទៅជាម៉ាស៊ីនប្រើប្រាស់ឧស្ម័ន ចេញពីឡជីវឧស្ម័នវិញ

- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសាកលវិទ្យាល័យ Kansas State University ស្តីពីកិច្ចសហការលើការបណ្តុះបណ្តាលនិងផ្តល់មូលនិធិស្រាវជ្រាវសម្រាប់បង្កើតផលិតផលនិងសេវាកម្មថ្មីបម្រើវិស័យឯកជន

- បានលើកគម្រោងសំណើស្រាវជ្រាវចំនួន៨ដើម្បីដាក់ជូនគណៈកម្មការត្រួតពិនិត្យគម្រោងស្រាវជ្រាវរបស់គម្រោងពង្រឹងគុណភាពឧត្តមសិក្សា (HEIP)។

### ១៧.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៥៣០នាក់ (ស្រី២៧២នាក់) លើជំនាញៈ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- សិក្សាពិសោធស្តីពីការលូតលាស់ដំណាំសណ្តែកផ្កាយនៅស្ថានីយពិសោធន៍កសិកម្មខេត្តតាកែវ

- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េជំរុញការស្រាវជ្រាវផ្នែកជាលិកាវប្បកម្ម

- បន្តសហការជាមួយ Cambodia - Japan Research Center for Agriculture ជំរុញការស្រាវជ្រាវលើដំណាំចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងផ្ទះសំណាញ់

- បន្តសហការជាមួយក្រុមហ៊ុនចិនពិសោធលើការចិញ្ចឹមត្រីបបែល

- ពិសោធការដាំផ្កាក្រដាស ផ្កាដកខឹម ផ្សាំផ្កាហុកគៀន និងប៉េងប៉ោះ

- បណ្តុះជាលិកាអ័រគីដេ និងចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងមន្ទីរពិសោធន៍ ដាំពិសោធចេកក្រម៉ូន ចេកស្វេង និងដាំពោតផ្អែមដែលនាំមកពីប្រទេសជប៉ុន

- ពិសោធចិញ្ចឹមគោយកសាច់ចំនួន ១៦ក្បាល ក្របីចំនួន ២ក្បាល ពិសោធចិញ្ចឹមត្រី និងកំពិស

- ធ្វើការបណ្តុះជាលិការុក្ខជាតិផ្សេងៗ និងវាស់កម្រិតជាតិអាស៊ីតក្នុងផលិតផលសៀងកែច្នៃ

- អនុវត្តលើមុខវិជ្ជាបរាសិតសាស្ត្រទៅលើការពិនិត្យមើលលាមកគោ ដើម្បីរកវត្តមានស៊ុតហ្វាស្យូឡា ការវិភាគរកវាយនភាពដី និងរបៀបវិភាគរកបាស

- ដឹកនាំនិស្សិតវិទ្យាសាស្ត្រកសិកម្មដាំបន្លែពិសោធន៍ និងនិស្សិតវិទ្យាសាស្ត្រកសិកម្មឆ្នាំទី២ ទី៣ បណ្តុះជាលិការុក្ខជាតិ លាយសារធាតុគីមីសម្រាប់បណ្តុះគ្រាប់អ័រគីដេ។

### ១៧.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៨-២០១៩ សរុបមានចំនួន ៦៥៩នាក់ (ស្រី២៩៦នាក់) លើជំនាញវិទ្យា-សាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ជលផល

- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- បានរៀបចំសាកល្បងផលិតមេជី *Lacto bacillus* និងពិសោធឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- ពិសោធប្រៀបធៀបការបំផ្លាញរបស់កគ្គាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ដង្កូវនាងព្រៃ

- បានបន្តផ្តល់ពូជដង្កូវនាងព្រៃឱ្យកសិករចិញ្ចឹមចំនួន ១០គ្រួសារនៅភូមិសំបូរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសសម្រេចបានចំនួន ៥២៨ ១៣៦ហ.ត ស្មើនឹង១១៤,៩១% នៃផែនការ ៤៥៩ ៥៩៤ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៩ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាននិងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត
- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ
- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ និងធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។

### ២ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើ

សភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត។

### ៣ ផ្នែកព្រៃឈើ

- បន្តសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដើម្បីចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរសត្វព្រៃ និងបន្តប្រមូលព័ត៌មាន ជំរុញការចុះបញ្ជិកានៃការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ សួនសត្វ និងកសិដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

- បន្តចុះតាមដានត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងារពាក់ព័ន្ធការកាប់រានដីព្រៃឈើ ចូលរួមសហការការងារជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើ

- បន្តជំរុញការងារបណ្តុះកូនឈើសម្រាប់ ចែកចាយដល់កសិករដាំអាស្រ័យផល និងចុះសិក្សាទីតាំងដីសម្រាប់បង្កើតជាស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

- បន្តការងារស្រាវជ្រាវក្រពើភ្នំ និងបង្រៀនប្រជាសហគមន៍ពីបច្ចេកទេសកសិកម្ម និងការចិញ្ចឹមសត្វ

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ។

### ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយុទ្ធការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គា ក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេសនៃការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសម

ស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពីកសិកម្មបែបវិបុលវប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ថ្ងៃ សុក្រ ៨ រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**